ក្រសួងសុខាភិបាល

លេខ......៦៣៣.........ស.ន.ប

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ប្រកាស

## ស្តីពី

## ការធ្វើប្រតិភូកម្មមុខងារ នៃវិស័យសុខាភិបាល ជូនការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុក ខណ្ឌគោលដៅ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាច្រកកម្ពុជា
- បានឃើញព្រះរាជក្រឹត្យនស / រកត ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញច្បាប់ ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០០/១០ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញសេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតការិយាល័យ ច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ
- បានឃើញប្រកាសលេខ ០០១៤ អបស/ឱអបស ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ ស្តីពីបែបបទ និងល័ក្ខខ័ណ្ឌក្នុងការសុំបើកឬបិទ ឬសុំប្តូរទីតាំងនៃគ្រឹះស្ថានឱសថ
- បានឃើញប្រកាសលេខ ០៣៤ អបស/មព ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការកែសម្រួលបែបបទ និងល័ក្ខខ័ណ្ឌបច្ចេកទេស ក្នុងការសុំបើកឬបិទ សុំកែទ្រង់ទ្រាយ ឬប្តូរទីតាំង នៃសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន
- បានឃើញប្រកាសលេខ៩២៨ ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុក ខ័ណ្ឌគោលដៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសម្រេចលេខ៤៧ សស់រ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយសាកល្បងនៅស្រុកសៀមរាប ខេត្តសៀមរាប ស្រុកបាត់ដំបង ខេត្តបាត់ដំបង
- បានឃើញសេចក្តីសម្រេចលេខ១៣២៩ សសរ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃ ស្តីពីការកំណត់ក្រុងគោលដៅ នៃគំរោងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ សម្រាប់អនុវត្តក្នុងឆ្នាំទីពីរ (២០១០-២០១១)
- បានឃើញលិខិតលេខ ៦៤ អ.រ.ម ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩របស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដោយមានចំណារឯកភាពរបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្តីពីការផ្លាស់ប្តូរឈ្មោះស្រុក ខ័ណ្ឌគោលដៅ នៃគំរោងការិយាល័យច្រក ចេញចូលតែមួយ

-យោងលិខិតលេខ៤៣៧ លស ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ ស្តីពីសំណើសុំរៀបចំដាក់ចេញប្រកាសប្រតិភូកម្មមុខងារក្នុងការផ្តល់សេវារដ្ឋបាលទៅក្រុង ស្រុក ខណ្ឌដែលមានការិយាល័យច្រកចេញចូលតែមួយ

## សម្រេច

**ប្រការ ១.-**

ត្រូវបានធ្វើប្រតិភូកម្មមុខងារ ពីក្រសួងសុខាភិបាល ជូនដល់ការិយាល័យច្រកចេញចូលតែមួយនៅក្រុងចំនួន៤ និងខណ្ឌចំនួន៨ នៃរាជធានីភ្នំពេញបន្ថែមទៀត ក្នុងការចេញលិខិតអនុញ្ញាត សុំបើក ឬ បិទ ឬ ប្តូរទីតាំង និងបន្តសុពលភាពសេវាឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ។

**ប្រការ ២.-**

ការិយាល័យច្រកចេញចូលតែមួយនៅក្រុង និងខណ្ឌនៃរាជធានីភ្នំពេញ ដែលត្រូវទទួលមុខងារក្នុងការចេញលិខិតអនុញ្ញាតដូចចែងក្នុងប្រការ ១មានៈ

| | |
|---|---|
| ១-ក្រុងកំពង់ចាម | នៃខេត្តកំពង់ចាម |
| ២-ក្រុងព្រៃវែង | នៃខេត្តព្រៃវែង |
| ៣-ក្រុងស្វាយរៀង | នៃខេត្តស្វាយរៀង |
| ៤-ក្រុងសិរីសោភ័ណ | នៃខេត្តបន្ទាយមានជ័យ |
| ៥-ខណ្ឌមានជ័យ | នៃរាជធានីភ្នំពេញ |
| ៦-ខណ្ឌចំការមន | នៃរាជធានីភ្នំពេញ |
| ៧-ខណ្ឌ៧មករា | នៃរាជធានីភ្នំពេញ |
| ៨-ខណ្ឌសែនសុខ | នៃរាជធានីភ្នំពេញ |
| ៩-ខណ្ឌពោធិ៍សែនជ័យ | នៃរាជធានីភ្នំពេញ |
| ១០-ខណ្ឌដង្កោ | នៃរាជធានីភ្នំពេញ |
| ១១-ខណ្ឌឫស្សីកែវ | នៃរាជធានីភ្នំពេញ |
| ១២-ខណ្ឌទួលគោក | នៃរាជធានីភ្នំពេញ |

**ប្រការ ៣.-**

សេវាឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រដែលត្រូវធ្វើប្រតិភូកម្មជូនការិយាល័យច្រកចេញចូលតែមួយនៅក្រុង និងខណ្ឌគោលដៅក្នុងការចេញលិខិតអនុញ្ញាតមាន ៖

-បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះមុននឹងក្រោយសម្រាល គ្រប់គ្រងដោយឆ្មប ដែលមានកំរិតបរិញ្ញាបត្ររងឆ្មប ឬសញ្ញាបត្រសមមូលឡើងទៅទទួលស្គាល់ដោយក្រសួងសុខាភិបាល។

-បន្ទប់ព្យាបាលដោយចលនា គ្រប់គ្រងដោយអ្នកព្យាបាលដោយចលនា ដែលមានកំរិតបរិញ្ញាបត្ររងព្យាបាលដោយចលនា ឬសញ្ញាបត្រសមមូលឡើងទៅ ទទួលស្គាល់ដោយក្រសួងសុខាភិបាល។

-បន្ទប់ថែទាំជំងឺ គ្រប់គ្រងដោយគិលានុបដ្ឋាក ដែលមានកំរិតបរិញ្ញាបត្ររងគិលានុបដ្ឋាក ឬសញ្ញាបត្រសមមូលឡើងទៅ ទទួលស្គាល់ដោយក្រសួងសុខាភិបាល។

-ឱសថស្ថានរង គ្រប់គ្រងដោយឱសថការីមធ្យម ដែលមានសញ្ញាបត្រទទួលស្គាល់ដោយក្រសួងសុខាភិបាល។

**ប្រការ ៤.-**

មន្ត្រីទទួលបន្ទុកបច្ចេកទេសសុខាភិបាល ត្រូវរៀបចំគំរូបែបបទផ្សេងៗ រួមទាំងឯកសារពាក់ព័ន្ធ សម្រាប់ការចេញលិខិតអនុញ្ញាតទៅតាមប្រភេទសេវាសុខាភិបាលដូចចែងក្នុងប្រការ៣ ។

**ប្រការ ៥.-**

ការអនុវត្តលើគំរូបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត របស់ការិយាល័យច្រកចេញចូលតែមួយនៅក្រុង និងខណ្ឌគោលដៅ របស់មន្ត្រីជំនួយការ អភិបាលក្រុង និងខណ្ឌគោលដៅ ត្រូវកំណត់ដោយសេចក្តីណែនាំមួយដោយឡែករបស់ក្រសួងសុខាភិបាល។

**ប្រការ ៦.-**

សាលាក្រុង និងខណ្ឌគោលដៅ ដែលមានការិយាល័យច្រកចេញចូលតែមួយត្រូវធ្វើលិខិតចម្លងស្តីពីការផ្តល់លិខិតអនុញ្ញាតដូចចែងក្នុងប្រការ១និងផ្តល់របាយការណ៍ស្ថិតិប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំមកក្រសួងសុខាភិបាល តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

**ប្រការ ៧.-**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល និងប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្តពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- សាលារាជធានី-សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ៧
- ឯកសារ-កាលប្បវត្តិ